អាជ្ញាធរសវនកម្មជាតិ
លេខៈ០៤៨/១១......អសជ/.ឝឝ

# សេចក្ដីសម្រេច

## ស្ដីពី

# ការបង្កើតការិយាល័យបន្ថែម ស្ថិតក្រោមនាយកដ្ឋានបច្ចេកទេស

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខៈ ០២៥/១១ ...អសជ/សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតការិយាល័យបន្ថែមស្ថិតក្រោមនាយកដ្ឋានបច្ចេកទេស

## អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខជស/រកម/០៣០០/១០ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/១១០០/១១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់បន្ថែមលើច្បាប់សវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០៦/០២៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០០៦/៤១៩ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីការតែងតាំងអគ្គសវនករ អគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញសេចក្តីសម្រេចលេខ០០៣/០១ អសជ/សសរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រង នៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញសេចក្តីសម្រេចលេខ០២០/០៥ អសជ/សសរ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង នៃអាជ្ញាធរសវនកម្មជាតិ
- ពិនិត្យឃើញការចាំបាច់របស់អាជ្ញាធរសវនកម្មជាតិ

## <u>សម្រេច</u>

**ប្រការ១** : ត្រូវបានបង្កើតការិយាល័យបន្ថែមស្ថិតក្រោមនាយកដ្ឋានបច្ចេកទេស បំពេញបន្ថែមក្នុងសេចក្តីសម្រេចលេខ០២០/០៥ អសជ/សសរ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង នៃអាជ្ញាធរសវនកម្មជាតិ ដូចខាងក្រោមៈ

១ - ការិយាល័យទំនាក់ទំនងអន្តរជាតិ
២ - ការិយាល័យកិច្ចការសាធារណៈ
៣ - ការិយាល័យទំនាក់ទំនងផ្ទៃក្នុង

**ប្រការ២** : ការិយាល័យនីមួយៗ មានភារកិច្ច ដូចតទៅៈ

១ - ការិយាល័យទំនាក់ទំនងអន្តរជាតិ ៖

- ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូល(INTOSAI) អង្គការអាស៊ី នៃស្ថាប័នសវនកម្មកំពូល(ASOSAI) ស្ថាប័នសវនកម្មកំពូល នៃបណ្តាប្រទេស (SAIs) ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា
- រៀបចំ និងតាមដានការអនុវត្តន៍កិច្ចព្រមព្រៀង ឬអនុស្សរណៈ នៃការយោគយល់គ្នារវាងស្ថាប័នសវនកម្មកំពូល ដៃគូអភិវឌ្ឍន៍នានា ជាមួយអាជ្ញាធរសវនកម្មជាតិ

លេខ ១៦ ផ្លូវ ២៤០ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
6. St 240, Sangkat Chak Tomuk. Khan Daun Penh, Phnom Penh. CAMBODIA
ទូរស័ព្ទ / ទូរសារលេខ (៨៥៥-២៣) ២១៥ ៣២០ អ៊ីម៉ែល : naakh@naa.gov.kh
Tel / Fax (855-23) 215 320 E-mail: naakh@naa.gov.kh

- សិក្សា តាមដានការងារ និងសេចក្ដីសម្រេចនានា របស់អង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូល និងអង្គការអាស៊ី នៃស្ថាប័នសវនកម្មកំពូល
- ពិនិត្យ និងតាមដានអំពីស្ថានភាព និងការវិវត្តន៍ នៃព្រឹត្តិការណ៍អន្តរជាតិទាក់ទងនឹងស្ថាប័នសវនកម្មកំពូល
- សម្របសម្រួលដំណើរទស្សនកិច្ចគណៈប្រតិភូក្នុងប្រទេស និងក្រៅប្រទេស របស់អាជ្ញាធរសវនកម្មជាតិ
- សហការរៀបចំកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា ថ្នាក់អន្តរជាតិ។

២ - ការិយាល័យកិច្ចការសាធារណៈ ៖
- ទំនាក់ទំនងជាមួយគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម និងគណៈកម្មការជំនាញនានា នៃរដ្ឋសភា និងព្រឹទ្ធសភា
- ទំនាក់ទំនង និងសហការជាមួយសវនកម្មផ្ទៃក្នុងនៃបណ្ដាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈនានា
- ផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអំពីតួនាទី ភារកិច្ច ការអនុវត្តន៍ និងលទ្ធផលការងាររបស់អាជ្ញាធរសវនកម្មជាតិដល់អង្គភាពរងសវនកម្ម និងសាធារណជន ។

៣ - ការិយាល័យទំនាក់ទំនងផ្ទៃក្នុង ៖
- ជាលេខាធិការ នៃគណៈកម្មការធានាគុណភាពសវនកម្ម
- ជាលេខាធិការនៃក្រុមការងាររៀបចំរបាយការណ៍សវនកម្មសម្រាប់ផ្សព្វផ្សាយជាសាធារណៈ
- ចូលរួមរៀបចំ តាមដាន និងបូកសរុបការអនុវត្តន៍ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរសវនកម្មជាតិ
- សម្របសម្រួលដល់ក្រុមការងារបច្ចេកទេសផ្សេងៗ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានការិយាល័យមួយចំនួនជាជំនួយការ។

**ប្រការ៣** : ឧបសម្ព័ន្ធ«ក» នៃសេចក្ដីសម្រេចលេខ០២០/០៥ អសជ/សសរ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង នៃអាជ្ញាធរសវនកម្មជាតិ ត្រូវបានបំពេញបន្ថែមតាមឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយនេះ។

**ប្រការ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងនាយកដ្ឋាននានាចំណុះអាជ្ញាធរសវនកម្មជាតិ មានភារកិច្ចអនុវត្តតាមសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១

អគ្គសវនករ

**គាត ឈន**

<u>ចម្លងជូន</u>
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
«ដើម្បីជូនជ្រាប »
-ដូចប្រការ៥ «ដើម្បីអនុវត្ត»
-ឯកសារ -កាលប្បវត្តិ

# រចនាសម្ព័ន្ធបំពេញបន្ថែម

យោង : សេចក្តីសម្រេចលេខ០២០/០៥ អសជ/សសរ
ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥
ឧបសម្ព័ន្ធ-ក- នៃសេចក្តីសម្រេចលេខ០៧៥/១១ សអជ.សសរ
ចុះថ្ងៃទី ១៤ ខែ៧ ឆ្នាំ២០១១

